# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ ២៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបញ្ចប់ សុពលភាពលិខិតអនុញ្ញាតយកអាវុធតាមខ្លួន
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្ដីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ

-ដើម្បីធានាស្ថិរភាព សុវត្ថិភាព សណ្ដាប់ធ្នាប់សង្គម

**សម្រេច**

**ប្រការ ១** ត្រូវបានបញ្ចប់សុពលភាពលិខិតអនុញ្ញាតយកអាវុធតាមខ្លួន ចេញអោយដោយអាជ្ញាធរណាក្ដី ក្រសួង ស្ថាប័ន ឬ មន្ត្រីណាក្ដី ក្រៅពីលក្ខខ័ណ្ឌ ដែលបានកំណត់ក្នុងមាត្រា ៨ មាត្រា ៩ និង មាត្រា ១០ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ។

**ប្រការ ២** ជនណាប្រព្រឹត្តល្មើសនឹងប្រការ ១ នៃសេចក្ដីសម្រេចនេះត្រូវផ្ដន្ទាទោសតាមមាត្រា ២ និងមាត្រា ៥ ច្បាប់ស្ដីពីការផ្ដន្ទាទោសការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជាដែលប្រកាសអោយប្រើដោយក្រឹត្យលេខ១១ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩២ ។

**ប្រការ ៣** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងខេត្ត-ក្រុង ត្រូវអនុវត្តសេចក្ដីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

ចម្លងជូន
-ខុទ្ទកាល័យ ព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ដូច ប្រការ ៤
-ឯកសារ-កាលប្បវត្តិ